**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០២១-២០២២
## ថ្ងៃចន្ទ ៨កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
## ត្រូវនឹងថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២២

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!*
*សម្ដេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល!*
*ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*
*លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្សជាទីស្រឡាញ់រាប់អាន និងបងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!*

ក្នុងឱកាសដ៏មានអត្ថន័យនៃថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២១-២០២២ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ ក្នុងនាមប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្ដែងនូវក្ដីសោមនស្សរីករាយក្រៃលែង និងប្រកបដោយភាពស្និទ្ធស្នាលជាមួយបងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្ស ទាំងអស់គ្រប់កម្រិតសិក្សា ដែលកំពុងអបអរសាទរការបើកបវេសនកាលឆ្នាំសិក្សាថ្មី នៅទូទាំងព្រះរាជាណាចក្រកម្ពុជានាថ្ងៃនេះ។

ខ្ញុំព្រះករុណា ខ្ញុំសូមយកឱកាសនេះ សូមថ្លែងអំណរគុណដ៏ស្មោះចំពោះថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាល សប្បុរសជន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ជាពិសេសលោកគ្រូ អ្នកគ្រូ ដែលបានពុះពារឧបសគ្គគ្រប់បែបយ៉ាងប្រកបដោយស្មារតីសាមគ្គីភាព ភក្ដីភាព និងមុះមុត ក្នុងការឧបត្ថម្ភគាំទ្រ និងធានាផ្ដល់នូវការរៀនសូត្រតាមគ្រប់រូបភាពដល់សិស្សានុសិស្ស ក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ អស់រយៈពេលជិត ២ឆ្នាំកន្លងមកនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណា ខ្ញុំសូមរំលឹកឡើងវិញថា ចាប់តាំងពីមានការរាតត្បាតនៃជំងឺកូវីដ-១៩ នៅខែមីនា ឆ្នាំ២០២០ រហូតមកទល់បច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា

បានដាក់ចេញនូវវិធានការដ៏មានប្រសិទ្ធភាពនិងប្រយ័ត្នប្រយែង ព្រមទាំងអាចកត់ត្រាទុកនិងរៀនសូត្រជាមេរៀនបទពិសោធ សម្រាប់ការអនុវត្ត "គន្លងប្រក្រតីភាពថ្មីនៃវិស័យអប់រំ" រួមមាន៖

ទី១- ការយកចិត្តទុកដាក់ដល់អាយុជីវិតរបស់បុគ្គលិកអប់រំនិងសិស្សានុសិស្សជាកត្តាអាទិភាព

ទី២- ការអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវវិធានការសុវត្ថិភាព សុខភាពសម្រាប់បុគ្គលិកអប់រំនិងសិស្សានុសិស្ស នៅតាមគ្រឹះស្ថានសិក្សាស្របតាមគោលការណ៍ "៣កុំ ៣ការពារ" តាមរយៈការអប់រំ ការផ្សព្វផ្សាយ និងការជួយគាំទ្រអំពីវិធានការការពារខ្លួនពីការឆ្លងកូវីដ-១៩

ទី៣- ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារអនាម័យ បង្គន់អនាម័យ និងទឹកស្អាត នៅតាមគ្រឹះស្ថានសិក្សាឱ្យបានគ្រប់គ្រាន់

ទី៤- ការរៀបចំនិងអភិវឌ្ឍប្រព័ន្ធអប់រំតាមបែបអេឡិចត្រូនិក ការអប់រំបែបឌីជីថល និងការអប់រំពីចម្ងាយឱ្យសម្បូរបែប និងចែកផ្សាយឱ្យបានទូលំទូលាយ

ទី៥- ការអនុញ្ញាតឱ្យដំណើរការគ្រឹះស្ថានសិក្សាឡើងវិញតាមបណ្តុំ តាមដំណាក់កាល និងប្រកបដោយការប្រុងប្រយ័ត្ន

ទី៦- ការអនុវត្តវិធានការគ្រប់គ្រងនិងរដ្ឋបាលតាមប្រព័ន្ធឌីជីថល ដែលមានប្រសិទ្ធភាព និង

ទី៧- ការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ជូនបុគ្គលិកអប់រំនិងសិស្សានុសិស្សឱ្យបានគ្រប់គ្នា។

វិធានការខាងលើនេះ បានធានាឱ្យបុគ្គលិកអប់រំអាចបន្តបំពេញការងារនិងសិស្សានុសិស្សនៅគ្រប់ភូមិសិក្សាអាចទទួលបានសេវាអប់រំតាមគ្រប់រូបភាព និងខ្ញុំនៅតែសង្កត់ធ្ងន់ថា វិធានការទាំងនេះនៅតែមានសុពលភាពបន្តទៀត ក្នុងបរិបទដែលកូវីដ-១៩ ឬមេរោគបំប្លែងថ្មី មិនទាន់រលាយបាត់។

រាជរដ្ឋាភិបាលកម្ពុជាបានមើលឃើញថា៖ នៅខែកញ្ញា ឆ្នាំ២០២១ ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតឱ្យចាប់ផ្តើមដំណើរការរៀននិងបង្រៀនជាលក្ខណៈបណ្តុំនៅតាមគ្រឹះស្ថានសិក្សាចំណោះទៅ និងការបើកដំណើរការឡើងវិញនៃគ្រឹះស្ថានឧត្តមសិក្សាដោយរលូន និងពុំមានហេតុការណ៍អ្វីកើតឡើងគួរកត់សម្គាល់ពាក់ព័ន្ធនឹងកត្តាសុខភាពរបស់បុគ្គលិកអប់រំនិងសិស្សានុសិស្ស រួមជាមួយនឹងកំណើនភាគរយខ្ពស់នៃការចាក់វ៉ាក់សាំងការពារកូវីដ-១៩ ជូនកុមារអាយុ៥ឆ្នាំ កុមារអាយុ៦ដល់១៧ឆ្នាំ និងប្រជាជនអាយុ១៨ឆ្នាំឡើង ជាពិសេសដំណើរការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំ២០២១ បានប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងជោគជ័យ។ ម្យ៉ាងវិញទៀតនៅក្នុងខែធ្នូ ឆ្នាំ២០២១ ខ្ញុំព្រះករុណា ខ្ញុំបានប្រកាសបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ២០២១ និងបានសម្រេចដាក់ឱ្យប្រើប្រាស់នូវ "ក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣" ជាមួយនឹងទស្សនវិស័យនៃការចាកចេញពីវិបត្តិនៃជំងឺកូវីដ-១៩ ក្នុងភាពរឹងមាំនិងការវិលត្រឡប់ទៅរកមាគ៌ានៃកំណើននិងការអភិវឌ្ឍប្រកបដោយចីរភាពឡើងវិញ។ កត្តាទាំងនេះហើយបានផ្តល់លទ្ធភាពឱ្យកម្ពុជាអាចប្រារព្ធពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២១-២០២២ ដ៏មានសារៈសំខាន់នាថ្ងៃនេះ សម្រាប់គ្រឹះស្ថានសិក្សានៅទូទាំងប្រទេស ក្រោមទស្សនាទាន ថ្មីគឺ "គន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ"។

*កូនៗសិស្សានុសិស្ស ជនរួមជាតិជាទីស្នេហា!*

ក្រសួងអប់រំ យុវជន និងកីឡាបានកំណត់យកថ្ងៃទី១០ ខែមករា ឆ្នាំ២០២២ គឺជាថ្ងៃបើកទំព័រថ្មី នៃការចាប់ផ្ដើមជីវិតសិក្សាដំបូងរបស់កូនៗ ដែលទើបនឹងដល់អាយុត្រូវចូលសាលារៀន និងជាថ្ងៃចូលរៀនក្នុងឆ្នាំសិក្សាថ្មីរបស់កូនៗជាសិស្សានុសិស្ស ជាកុលបុត្រ កុលធីតាជាទីស្រឡាញ់របស់យើងគ្រប់ៗគ្នានៅក្នុង "គន្លងប្រក្រតីភាពថ្មីនៃវិស័យអប់រំ" ។

ក្នុងឱកាសដ៏វិសេសនេះ ដើម្បីឱ្យដំណើរការឆ្នាំសិក្សាថ្មី ២០២១-២០២២ ទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមលើកឡើងនូវចំណុចមួយចំនួន ដូចខាងក្រោម៖

ទី១- ក្រសួងអប់រំ យុវជន និងកីឡាត្រូវបន្តដឹកនាំនិងអនុវត្តនូវទស្សនាទានថ្មី "គន្លងប្រក្រតីភាពថ្មីក្នុងវិស័យអប់រំ" ដោយសូមគិតគូរអំពីជម្រើសនិងអភិវឌ្ឍធនធានបង្រៀននិងរៀនឱ្យបានច្រើនសម្បូរបែប ដើម្បីធានាផ្ដល់សេវាអប់រំ ដែលមានភាពឆ្លើយតបនិងរស់រវើក ជាពិសេសដំណើរការបង្រៀននិងរៀនដែលមានភាពទន់ភ្លន់ និងតាមទម្រង់នៃវិមជ្ឈការនិងវិសហមជ្ឈការនៃសេវាអប់រំ។

ទី២- ក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធ ត្រូវបន្តជំរុញ "ការអប់រំឌីជីថល និងការអប់រំពីចម្ងាយ" ឱ្យទាន់សភាពការណ៍ជាតិ តំបន់ និងសកលលោក។

ទី៣- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើការពិនិត្យឡើងវិញឱ្យស្របនឹងបរិបទថ្មីៗ ដែលតម្រូវឱ្យធ្វើការអភិវឌ្ឍសមត្ថភាពនិងការកសាងប្រព័ន្ធអប់រំដ៏រឹងមាំ ដែលមានភាពរស់រវើក មានគណនេយ្យភាព និងកាន់តែធានាបាននូវភាពសក្តិសិទ្ធិនៃការដឹកនាំ និងគ្រប់គ្រងរបស់បុគ្គលិកនៅគ្រប់លំដាប់ថ្នាក់ ជាពិសេសការគ្រប់គ្រងនៅកម្រិតសាលារៀន រួមបញ្ចូលទាំងប្រសិទ្ធភាពនៃការគ្រប់គ្រងគ្រូបង្រៀន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងវិស័យអប់រំ, ការបង្កើនប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ, ការអនុវត្តវិមជ្ឈការនិងវិសហមជ្ឈការក្នុងវិស័យអប់រំ, និងការអភិវឌ្ឍសមត្ថភាពនិងវិជ្ជាជីវៈជាប្រចាំដល់អ្នកគ្រប់គ្រង នាយកសាលា និងគ្រូបង្រៀន។

ទី៤- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបន្តផ្ដោតការយកចិត្តទុកដាក់លើការអប់រំឆ្លើយតបទៅនឹងទីផ្សារការងារដោយអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗក្នុងសតវត្សទី២១ និងការផ្ដោតលើការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ដែលនឹងបណ្ដុះបាននូវអ្នកជំនាញចាំបាច់ក្នុងយុគសម័យឌីជីថល និងសេដ្ឋកិច្ចឌីជីថល។

ទី៥- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវរៀបចំប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមទាំងវគ្គក្រឹតការតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពរបស់គ្រូបង្រៀនគ្រប់កម្រិត ជាពិសេសការបង្រៀននិងរៀនតាមបែបបច្ចេកវិទ្យាទំនើប។

ទី៦- ក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានសិក្សាគ្រប់កម្រិត ត្រូវខិតខំពង្រីកសក្ដានុពលរបស់ខ្លួនទាំងខាងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ទាំងសេវាបង្រៀននិងរៀន ដើម្បីឱ្យសាលារៀនរបស់យើងក្លាយទៅជាសាលាកុមារមេត្រីកម្រិតអភិវឌ្ឍន៍, ជាសាលារៀនជំនាន់ថ្មី, និងជាសាលារៀនដែលមានប្រសិទ្ធភាព។ ជាមួយគ្នានេះ ត្រូវខិតខំកែលម្អនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្មីៗ ដូចជាបន្ទប់រៀនទំនើប បន្ទប់ពិសោធ បន្ទប់កុំព្យូទ័រ និងបន្ទប់សាស្ត្រាចារ្យ តាមលទ្ធភាពនិងស្ថានភាពជាក់ស្ដែងរបស់សាលារៀន សម្រាប់បម្រើដល់ការបង្រៀននិងរៀនតាមបែបថ្មីដោយប្រើប្រាស់បច្ចេកវិទ្យា។

ទី៧- សូមគ្រប់គ្រឹះស្ថានសិក្សា បន្តលើកកម្ពស់សុខភាពអនាម័យក្នុងបរិបទកូវីដ-១៩ ដោយអនុវត្តតាមអភិក្រម"៣កុំ ៣ការពារ" ជាពិសេសសូមមានវិធានការឆ្លើយតបនិងចូលរួមទប់ស្កាត់ភ្លាមៗដើម្បីការពារកុំឱ្យមានការឆ្លងកូវីដ-១៩ នៅក្នុងគ្រឹះស្ថានសិក្សា រួមទាំងបង្កើនការអប់រំអំពីសុវត្ថិភាពសុខភាពសិក្សា ការរក្សាគម្លាតសុវត្ថិភាព និងសុវត្ថិភាពចំណីអាហារដល់បុគ្គលិកអប់រំ និងសិស្សានុសិស្ស ព្រមទាំងត្រូវយកចិត្តទុកដាក់ក្នុងការគាំទ្រសុខភាពផ្លូវចិត្តនិងផ្លូវកាយរបស់សិស្សានុសិស្ស ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ឬប្រយោលពីជំងឺកូវីដ-១៩ និងត្រូវអនុញ្ញាតឱ្យពួកគេ ចូលរួមក្នុងការសម្រេចចិត្តទាំងឡាយដែលប៉ះពាល់ដល់ពួកគេ។

ទី៨- គ្រឹះស្ថានសិក្សាគ្រប់កម្រិតត្រូវបន្តរៀបចំបរិស្ថានសាលារៀនស្អាត សាលារៀនបៃតង មានទឹកស្អាត មានបង្គន់អនាម័យ កន្លែងលាង និងសួនធម្មជាតិ ។ល។ ឱ្យស័ក្តិសមជាទីកន្លែងសម្រាប់ការអប់រំ និងបណ្តុះគំនិតស្អាតស្អំ ឥរិយាបថល្អ និងគ្មានការញាំញីផ្លូវចិត្ត ផ្លូវកាយ។ ជាមួយគ្នានេះ គ្រឹះស្ថានសិក្សាត្រូវត្រៀមលក្ខណៈតាមគ្រប់រូបភាព ដើម្បីឆ្លើយតបឱ្យមានប្រសិទ្ធភាពនិងទាន់ពេលវេលា ក្នុងករណីមានប្រធានស័ក្តិកើតឡើង ដូចជាអាកាសធាតុក្តៅហួតហែង ទឹកជំនន់ ខ្យល់កន្ត្រាក់ និងការរាតត្បាតនៃជំងឺនានា ។ល។

ទី៩- សូមលោកគ្រូ អ្នកគ្រូទាំងអស់ បន្តដើរតួជាបុគ្គលនាំមុខជាឪពុកម្ដាយទី២, ជាមគ្គុទ្ទេសក៍, ជាអ្នកស្រាវជ្រាវ, ជាទីប្រឹក្សា, និងជាអ្នកវៃឆ្លាតប្រទិត ព្រមទាំងត្រូវខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពខ្លួនជាប្រចាំ ទាំងខាងផ្នែកចំណេះដឹង ទាំងវិធីសាស្ត្របង្រៀន រួមទាំងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស ដើម្បីយកចំណេះដឹងថ្មីៗ គរុកោសល្យថ្មីៗ មកបង្ហាត់បង្រៀនដល់សិស្សឱ្យមានចំណេះដឹងទូលំទូលាយ និងអភិវឌ្ឍខ្លួនទៅជាពលរដ្ឋសកលនិងជាអ្នកបន្តវេនសម្រាប់ថ្ងៃអនាគត។

ទី១០- សូមក្មួយៗ សិស្សានុសិស្ស យុវជន យុវនារីទាំងអស់ បន្តខិតខំរៀនសូត្រនិងស្រាវជ្រាវឱ្យបានខ្ជាប់ខ្ជួននិងចូលរួមឱ្យបានសស្រាក់សស្រាំក្នុង "អំពើល្អ" ដើម្បីការរីកចម្រើននៅក្នុងគ្រួសារ ក្នុងសង្គម និងប្រទេសជាតិយើងទាំងមូល ជាពិសេសត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន និងការប្រព្រឹត្តអំពើអបាយមុខផ្សេងៗ។

ទី១១- សូមមាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប នាំកូន នាំចៅ មកចុះឈ្មោះចូលរៀននិងបន្តផ្តល់ការគាំទ្រ ការលើកទឹកចិត្ត និងជួយបង្រៀនបន្ថែមដល់កូន ដល់ចៅតាមគ្រប់រូបភាព។

ទី១២- សូមក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី សហគមន៍ យកចិត្តទុកដាក់និងចូលរួមគាំទ្រឱ្យបានខ្លាំងក្លាថែមទៀតក្នុងការអភិវឌ្ឍសាលារៀន ព្រមទាំងបន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីការការពារកុមារពីអំពើហិង្សានិងពលកម្មកុមារគ្រប់ទម្រង់។

ទី១៣- សូមគ្រប់ស្ថានីយវិទ្យុ ទូរទស្សន៍របស់រដ្ឋ និងឯកជន និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ បន្តជួយផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពី យុទ្ធនាការនៃការប្រមូលកុមារចូលរៀន និងសារៈសំខាន់នៃការអប់រំ ជាពិសេសការផលិតកម្មវិធីអប់រំនិងវីដេអូបង្រៀន ដើម្បីឱ្យសេវាអប់រំកាន់តែបានឈានទៅដល់គ្រប់ទីកន្លែង គ្រប់ពេលវេលា ស្របទៅនឹងទស្សនាទាននៃការអប់រំពេញមួយជីវិត។

ជាថ្មីម្តងទៀត ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះតេជគុណ ព្រះសង្ឃគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ បុគ្គលិកអប់រំ លោកគ្រូ អ្នកគ្រូទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា ដែលតែងតែបានរួមចំណែកកសាងនិងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការរីកចម្រើនគួរជាទីមោទនៈ ក្នុងរយៈកាលកន្លងមកនេះ និងសូមបន្តជួយឧបត្ថម្ភគាំទ្រ និងផ្តល់នូវកិច្ចសហការល្អតទៅទៀត ដើម្បីបុព្វហេតុនៃការអភិវឌ្ឍធនធានមនុស្សនៅកម្ពុជា។

នៅទីបញ្ចប់ ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០២១-២០២២នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេនពរ ព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និងបងប្អូនជនរួមជាតិ ទាំងអស់នៅទូទាំងប្រទេស សូមប្រកបដោយពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

***សូមអរព្រះគុណ និងអរគុណ!***

ថ្ងៃអង្គារ ៣ កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**